  

# វគ្គផ្សព្វផ្សាយ អំពី
# កាកបាទក្រហមកម្ពុជា និងការសិក្សាតាមប្រព័ន្ធអនឡាញ

ធ្វើបច្ចុប្បន្នកម្មដោយ នាយកដ្ឋានទំនាក់ទំនង

ឆ្នាំ ២០២២





# វគ្គផ្សព្វផ្សាយ អំពី
# កាកបាទក្រហមកម្ពុជា និងការសិក្សាតាមប្រព័ន្ធអនឡាញ

ថ្ងៃពុធ ៨កើត ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០២២

# កាកបាទក្រហមកម្ពុជា

CAMBODIAN RED CROSS

## វត្ថុផ្សព្វផ្សាយ អំពី

## កាកបាទក្រហមកម្ពុជា និងការសិក្សាតាមប្រព័ន្ធអនឡាញ

# មាតិកា

- គោលការណ៍គ្រឹះ ៧ ប្រការ របស់ចលនាអន្តរជាតិ កាកបាទក្រហម និងអឌ្ឍចន្ទក្រហម
- សមាសភាគ របស់ចលនាអន្តរជាតិ កាកបាទក្រហម និងអឌ្ឍចន្ទក្រហម
- បដិរូបនៃភាពមនុស្សធម៌
- គោលការណ៍ណែនាំ ស្តីពី អត្តសញ្ញាណកាកបាទក្រហមកម្ពុជា
- ព្រះរាជក្រឹត្យស្តីពីការប្រើប្រាស់ និងការការពារ បដិរូបកាកបាទក្រហម និង អឌ្ឍចន្ទក្រហម
- ប្រវត្តិកំណើតកាកបាទក្រហមកម្ពុជា
- រចនាសម្ព័ន្ធ - មុខងារ និងភារកិច្ច
- យុទ្ធសាស្ត្រ ២០២១ - ២០៣០

# គោលការណ៍គ្រឹះ ៧ ប្រការ
# របស់ចលនាអន្តរជាតិ កាកបាទក្រហម និងអឌ្ឍចន្ទក្រហម

គោលការណ៍គ្រឹះបានប្រកាសជាផ្លូវការនៅទីក្រុងវីយែន (អូទ្រីស) ឆ្នាំ១៩៦៥ មាន៖



# គោលការណ៍គ្រឹះ ៧ ប្រការ
# របស់ចលនាអន្តរជាតិ កាកបាទក្រហម និងអឌ្ឍចន្ទក្រហម

គោលការណ៍គ្រឹះទាំង ៧ ប្រការ ( ត )

## ភាពមនុស្សធម៌ ( *ក្តីមេត្តា*)

* តស៊ូប្រឆាំងនឹងទុក្ខលំបាកវេទនា
* ធ្វើឲ្យធូរស្បើយពីទុក្ខវេទនា
* គោរពមនុស្សជាតិ
* យោគយល់គ្នា មិត្តភាព សហប្រតិបត្តិការ សន្តិភាព

## ភាពមិនលំអៀង

* មិនប្រកាន់ រើសអើងរវាងជនជាតិ ពូជសាសន៍ សាសនា ជំនឿ ភេទ វណ្ណៈ
* ទំហំសមាមាត្រជំនួយ/អាទិភាព ( ធំធេងចំពោះតម្រូវការជាអតិបរិមា )
  ជួយខ្លាំងចំពោះសេចក្តីត្រូវការខ្លាំងណាស់ដែរ
* ជាឧត្តមគតិសារវ័ន្តសម្រាប់ចលនា

# គោលការណ៍គ្រឹះ ៧ ប្រការ
# របស់ចលនាអន្តរជាតិ កាកបាទក្រហម និងអឌ្ឍចន្ទក្រហម

## អព្យាក្រឹតភាព

គោលការណ៍គ្រឹះទាំង ៧ ប្រការ ( ត )

* រក្សាជំនឿទុកចិត្តដល់ជនគ្រប់រូប
* មិនចូលរួមក្នុងអរិភាព និង វាទប្បដិវាទ
* អព្យាក្រឹតភាពចំពោះគ្រប់មតិ យោបល់ដែលខុសគ្នារវាង៖
  - ស្ថាប័ន គឺ អព្យាក្រឹតភាព
  - បុគ្គល គឺ ភាពមិនលំអៀង

## ឯករាជ្យភាព (*ទៅតាមគោលការណ៍*)

* សមាគមជាតិ ត្រូវតែឯករាជ្យ មានស្វ័យភាព
* ជានាភាពមិនលំអៀង និង អព្យាក្រឹតភាព
* ជាជំនួយការឲ្យអាជ្ញាធរសាធារណៈ បំពេញចន្លោះ សហការ មិនប្រកួតប្រជែង
* អនុលោមតាមច្បាប់របស់ប្រទេស មានឯករាជ្យភាព ស្វ័យភាព និងមានសេរីភាព ក្នុងការធ្វើសកម្មភាពក្នុងគោលបំណងគោរពគោលការណ៍គ្រឹះ

# គោលការណ៍គ្រឹះ ៧ ប្រការ
# របស់ចលនាអន្តរជាតិ កាកបាទក្រហម និងអឌ្ឍចន្ទក្រហម

គោលការណ៍គ្រឹះទាំង ៧ ប្រការ ( ត )

## សេវាកម្មស្ម័គ្រចិត្ត (*សមាជិកភាព និងសកម្មភាព*)

* មានជំនឿស៊ប់ និង ចូលរួមដោយសកម្ម
* មិនទទួលរង្វាន់ និង ដើម្បីជនរងគ្រោះ
* មិនយកកម្រៃ

## សកលភាព

* សកម្មភាពជាសកល
* សិទ្ធិស្មើគ្នា
* សាមគ្គីភាព

## ឯកភាព

* ប្រទេសមួយ សមាគមជាតិមួយ
* បើកទូលាយដល់គ្រប់តំណាងទាំងអស់
* ធានាភាពមិនលំអៀងនិងមិនរើសអើង
* ធ្វើសកម្មភាពទូទាំងប្រទេស

សមាគមជាតិទាំងអស់ត្រូវប្រកាន់ឲ្យបានខ្ជាប់ខ្ជួននូវគោលការណ៍គ្រឹះទាំង ៧ ខាងលើនេះ ក្នុងការបំពេញភារកិច្ច និង បេសកកម្មរបស់ខ្លួន។

# សមាសភាគរបស់
# ចលនាអន្តរជាតិ កាកបាទក្រហម និងអឌ្ឍចន្ទក្រហម

## សមាសភាគរបស់ចលនា មាន៣៖

១- គណៈកម្មាធិការអន្តរជាតិនៃកាកបាទក្រហម ដែលហៅកាត់ជាភាសាអង់គ្លេសថា អាយ.ស៊ី.អរ.ស៊ី (ICRC) ឬ ជាភាសាបារាំងថា សេ.អ៊ី.សេអ៊ែរ (CICR) ។

២- សហព័ន្ធអន្តរជាតិ នៃសមាគមកាកបាទក្រហម និងអឌ្ឍចន្ទក្រហម

៣- សមាគមជាតិ នៃប្រទេសនីមួយៗ (កាកបាទក្រហម ឬ អឌ្ឍចន្ទក្រហម)

ដែលរួមបញ្ចូលគ្នាបង្កើតបានជា ចលនាកាកបាទក្រហម ហើយនៅឆ្នាំ១៩៨៦

បានទទួលឈ្មោះជាផ្លូវការថា “ចលនាអន្តរជាតិ កាកបាទក្រហម និងអឌ្ឍចន្ទក្រហម” ហៅកាត់ថា “**ចលនា**”

# សមាសភាគរបស់
# ចលនាអន្តរជាតិ កាកបាទក្រហម និងអឌ្ឍចន្ទក្រហម

## សមាសភាគរបស់ចលនា មាន៣៖

ICRC

- គណៈកម្មាធិការអន្តរជាតិនៃកាកបាទក្រហម
- បង្កើតឡើងថ្ងៃទី ១៧ កុម្ភៈ ១៨៦៣ គឺជាអង្គការមិនលំអៀង អព្យាក្រឹត ឯករាជ្យ។ អាយ.ស៊ី.អរ.ស៊ី មានបេសកកម្មមនុស្សធម៌ដ៏ថ្លៃថ្លាបំផុត គឺគាំពារអាយុជីវិត និងសេចក្តីថ្លៃថ្នូររបស់ជនរងគ្រោះដោយសារសង្គ្រាម ដោយអំពើហិង្សាផ្ទៃក្នុង ហើយ និងផ្តល់ការឧបត្ថម្ភដល់ជនរងគ្រោះទាំងនោះ។

IFRC

- សហព័ន្ធអន្តរជាតិ នៃសមាគមកាកបាទក្រហម និងអឌ្ឍចន្ទក្រហម
- បង្កើតឡើងនៅថ្ងៃទី ៥ ខែឧសភា ឆ្នាំ១៩១៩
- ជាអ្នកចង្អុលទិស និងជាអ្នកសម្របសម្រួលដល់ការងារផ្តល់ជំនួយអន្តរជាតិ ជួយដល់ជនរងគ្រោះដោយមហន្តរាយគ្រប់ប្រភេទ ជួយដល់ជនភៀសខ្លួន និងគ្រោះបន្ទាន់ ផ្នែកសុខភាព។

# សមាសភាគរបស់
# ចលនាអន្តរជាតិ កាកបាទក្រហម និងអឌ្ឍចន្ទក្រហម



សមាគមជាតិ កាកបាទក្រហម និង អឌ្ឍចន្ទក្រហម

លើពិភពលោក មកទល់នឹងឆ្នាំ២០២២ មានចំនួន ១៩២

# បដិរូបនៃភាពមនុស្សធម៌

- បដិរូបទាំងបី អាចប្រើប្រាស់ជាឧបករណ៍សម្រាប់ការពារ
- ភាពខុសគ្នារវាង បដិរូប និង និមិត្តសញ្ញា
- ស្ថាប័ន និងអង្គភាពដែលអាចប្រើបដិរូប និង និមិត្តសញ្ញា

  កាកបាទក្រហម ឬ អឌ្ឍចន្ទក្រហម

# បដិរូបនៃភាពមនុស្សធម៌

## បដិរូបទាំងបី អាចប្រើប្រាស់ជាឧបករណ៍សម្រាប់ការពារ

- កាកបាទក្រហម បង្កើតនៅឆ្នាំ ១៨៦៣/១៨៦៤
- អឌ្ឍចន្ទក្រហម បង្កើតនៅឆ្នាំ ១៩២៩
- គ្រីស្តាល់ក្រហម បង្កើតនៅថ្ងៃទី៨ ធ្នូ ២០០៥

# បដិរូបនៃភាពមនុស្សធម៌

## ភាពខុសគ្នារវាង បដិរូប និង និមិត្តសញ្ញា

- ✓ បដិរូប គឺសញ្ញាកាកបាទក្រហម លើផ្ទៃពណ៌ស

- ✓ និមិត្តសញ្ញា គឺសញ្ញាកាកបាទក្រហម ឬ អឌ្ឍចន្ទក្រហម លើផ្ទៃពណ៌ស ហើយមានអក្សរនៅជុំវិញ

ឬ

# បដិរូបនៃភាពមនុស្សធម៌

## ស្ថាប័ន និងអង្គភាពដែលអាចប្រើបដិរូប និង និមិត្តសញ្ញា កាកបាទក្រហម ឬ អឌ្ឍចន្ទក្រហម

ICRC

គណៈកម្មាធិការអន្តរជាតិនៃកាកបាទក្រហម

IFRC

សហព័ន្ធអន្តរជាតិ នៃសមាគម កាកបាទក្រហម និងអឌ្ឍចន្ទក្រហម

សមាគមជាតិ
កាកបាទក្រហម ឬ អឌ្ឍចន្ទក្រហម

សេវាកម្មពេទ្យយោធា

# គោលការណ៍ណែនាំ
# ស្តីពី
# អត្តសញ្ញាណកាកបាទក្រហមកម្ពុជា

* គំរូមួកសុវត្ថិភាព
* គំរូអាវយឺត
* គំរូរថយន្ត
* សម្គាល់
* គំរូកន្ទាស់
* គំរូអាវកាក់
* គំរូហ្វុង
* ប្រការត្រូវជៀសវាង

# គោលការណ៍ណែនាំ ស្ដីពី អត្តសញ្ញាណ កក្រក

## គំរូមួកសុវត្ថិភាព



# គោលការណ៍ណែនាំ ស្ដីពី អត្តសញ្ញាណ កក្រក

គំរូកន្លាស់



# គោលការណ៍ណែនាំ ស្តីពី អត្តសញ្ញាណ កក្រក

## គំរូអាវយឺត



# គោលការណ៍ណែនាំ ស្ដីពី អត្តសញ្ញាណ កក្រក

## គំរូអាវកាក់






# គោលការណ៍ណែនាំ ស្ដីពី អត្តសញ្ញាណ កក្រក

## គំរូអាវកាក់



# គោលការណ៍ណែនាំ ស្តីពី អត្តសញ្ញាណ កក្រក











# គោលការណ៍ណែនាំ ស្តីពី អត្តសញ្ញាណ កក្រក



# គោលការណ៍ណែនាំ ស្ដីពី អត្តសញ្ញាណ កក្រក



# គោលការណ៍ណែនាំ ស្ដីពី អត្តសញ្ញាណ កក្រក

**សម្គាល់៖**

នៅពេលចូលភោជនីយដ្ឋាន ឬទីកន្លែងណា ដែលបណ្ដាលឲ្យសាធារណជនមាន ការយល់ច្រឡំសូមដោះកន្លាស់និមិត្តសញ្ញា កក្រក ចេញ។

**ប្រការត្រូវជៀសវាងដាច់ខាត៖**

ហាមដាច់ខាត មិនត្រូវខ្ទាស់កន្លាស់និមិត្តសញ្ញា កក្រក នៅលើឯកសណ្ឋានកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ (ទោះបីបុគ្គលនោះជាសមាជិក កក្រក ក៏ដោយ) និងអាវយឺតឬអាវ ដែលមាននិមិត្តសញ្ញាក្រុមហ៊ុន និងស្ថាប័នផ្សេងៗទៀត។

# គោលការណ៍ណែនាំ ស្ដីពី អត្តសញ្ញាណ កក្រក

## ហាមប្រើ

មិនត្រូវដាក់ ថែមអក្សរសាខា នៅក្បែរនិមិត្តសញ្ញា កក្រក ដែលបណ្ដាល ឲ្យមានការភ័ន្តច្រឡំ ឡូហ្គោរបស់សាខា។

សាខាកក្រកខេត្ត ? ? ?

មិនត្រូវដាក់ឈ្មោះសាខានៅក្នុងនិមិត្តសញ្ញា កក្រក ជាដាច់ខាត។

សម្គាល់៖ ត្រារបស់សាខា ទើបមានពាក្យ “សាខា .........”។

# ព្រះរាជក្រឹត្យ ស្ដីពីការប្រើប្រាស់ និងការការពារ បដិរូប
# កាកបាទក្រហម និង អឌ្ឍចន្ទក្រហម

* ព្រះរាជក្រឹត្យ នស/រកត/០៥០២/១១២ ស្ដីពីការប្រើប្រាស់ និង ការការពារបដិរូបកាកបាទក្រហម និង អឌ្ឍចន្ទក្រហម ឡាយព្រះហស្ដលេខា ថ្ងៃទី ៦ ខែ ឧសភា ឆ្នាំ ២០០២ មាន ៨ ជំពូក និង ១៦មាត្រា

- ការប្រើប្រាស់មិនត្រឹមត្រូវនូវបដិរូបកាកបាទក្រហម ឬ អឌ្ឍចន្ទក្រហម
- តើកាកបាទក្រហមកម្ពុជា ត្រូវធ្វើដូចម្ដេចពេលឃើញការប្រើប្រាស់បដិរូបខុស ?
- ករណីប្រើខុស

# ព្រះរាជក្រឹត្យ ស្តីពីការប្រើប្រាស់ និងការការពារ បដិរូប កាកបាទក្រហម និង អឌ្ឍចន្ទក្រហម

## ការប្រើប្រាស់មិនត្រឹមត្រូវនូវបដិរូបកាកបាទក្រហម ឬ អឌ្ឍចន្ទក្រហម

* អាជ្ញាធរត្រូវចាត់វិធានការសមស្រប ដើម្បីបង្ការនូវការប្រើខុស ជាពិសេសត្រូវធ្វើការផ្សព្វផ្សាយអំពីវិធាន ដែលបានលើកមកនេះឲ្យបានទូលំទូលាយតាមដែលអាចធ្វើបាន ក្នុងចំណោមកងកម្លាំងប្រដាប់អាវុធ កងកម្លាំងនគរបាល អាជ្ញាធរសាធារណៈ និងពលរដ្ឋស៊ីវិល។

យោងជំពូកទី៥ មាត្រា ៨ នៃព្រះរាជក្រឹត្យស្តីពីការប្រើប្រាស់ និងការការពារ បដិរូបកាកបាទក្រហម និង អឌ្ឍចន្ទក្រហម

# ព្រះរាជក្រឹត្យ ស្តីពីការប្រើប្រាស់ និងការការពារ បដិរូប កាកបាទក្រហម និង អឌ្ឍចន្ទក្រហម

## តើកាកបាទក្រហមកម្ពុជា ត្រូវធ្វើដូចម្តេចពេលឃើញការប្រើប្រាស់បដិរូបខុស ?

* កក្រក ត្រូវសហការយ៉ាងសកម្មជាមួយនឹងអាជ្ញាធរមានសមត្ថកិច្ច នៅក្នុងការខិតខំប្រឹងប្រែងរបស់ខ្លួនដើម្បីបង្ការ និង បង្ក្រាបការប្រើប្រាស់ខុសណាមួយ។

* កក្រក ត្រូវបានផ្តល់សិទ្ធិឲ្យជូនដំណឹងទៅរាជរដ្ឋាភិបាល អំពីការប្រើខុសណាមួយ ព្រមទាំងចូលរួមក្នុងការប្តឹងតាមផ្លូវច្បាប់ ឬ តាមផ្នែករដ្ឋបាលដែលពាក់ព័ន្ធ។

យោងជំពូកទី៥ មាត្រា ៩ នៃព្រះរាជក្រឹត្យស្តីពីការប្រើប្រាស់ និងការការពារ បដិរូបកាកបាទក្រហម និង អឌ្ឍចន្ទក្រហម

# ព្រះរាជក្រឹត្យ ស្ដីពីការប្រើប្រាស់ និងការការពារ បដិរូប កាកបាទក្រហម និង អឌ្ឍចន្ទក្រហម

## ក្នុងករណីប្រើខុស៖

- សមាគមជាតិ ធ្វើរបាយការណ៍ជូនអាជ្ញាធរ
- អាជ្ញាធរ មានតួនាទីដោះស្រាយតាមបែបបទ និងតាមច្បាប់
- អាយ.ស៊ី.អរ.ស៊ី រួមជាមួយសមាគមជាតិ ធ្វើការផ្ទាល់ជាមួយអាជ្ញាធរ

# កាកបាទក្រហមកម្ពុជា

CAMBODIAN RED CROSS

## ប្រវត្តិកំណើតកាកបាទក្រហមកម្ពុជា

- កាកបាទក្រហមកម្ពុជា បានបង្កើតឡើងនៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ១៩៥៥ ដែលកាលនោះមានឈ្មោះ "*សមាគមជាតិកាកបាទក្រហមខ្មែរ*" បានធ្វើឡើងក្រោយព្រះរាជាណាចក្រកម្ពុជាបានទទួលឯករាជ្យជាតិ និងជាការអនុវត្តតាមគោលគំនិតរបស់ លោក ហង់រី ឌុយណង់ ពាណិជ្ជករជាតិស្វីស ដែលបានឃើញច្បាស់នឹងភ្នែកនូវសោកនាដកម្មបង្កឡើងដោយសង្គ្រាមរវាងទ័ពបារាំង និងអ៊ីតាលី លើសមរភូមិសុលហ្វេរីណូ និងជាស្ថាបនិករបស់ចលនាអន្តរជាតិ កាកបាទក្រហម និងអឌ្ឍចន្ទក្រហម។

- សមាគមជាតិកាកបាទក្រហមខ្មែរ មានគណៈកម្មាធិការ១៥ នាក់ មាន *សម្តេចព្រះរាជកន្និដ្ឋា នរោត្តមរស្មី សោភ័ណ* ជាព្រះប្រធាន និងមានលោកជំទាវ ផ្លេក ភិរុណ ជាអគ្គហេរញ្ញិករង ធ្វើការពង្រឹងកម្លាំងមនុស្សធម៌ ដើម្បីជួយសង្គ្រោះប្រជារាស្ត្រកម្ពុជាទូទាំងប្រទេស។

# ប្រវត្តិកំណើតកាកបាទក្រហមកម្ពុជា

* សមាគមជាតិកាកបាទក្រហមខ្មែរ ដែលមានតួនាទីជាជំនួយការឲ្យអាជ្ញាធរសាធារណៈក្នុងវិស័យមនុស្សធម៌ ប្រមូលផ្តុំកម្លាំងមនុស្សធម៌ ដើម្បីជួយសម្រាលទុក្ខលំបាករបស់ប្រជានុរាស្ត្រងាយរងគ្រោះ និងរងគ្រោះក្នុងគ្រប់កាលៈទេសៈ។
* បានទទួលស្គាល់ដោយរាជរដ្ឋាភិបាលកម្ពុជា តាមរយៈព្រះរាជក្រឹត្យលេខ ៣៧៨ នសចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ១៩៥៨។
* ថ្ងៃទី៦ តុលា ១៩៦០ បានទទួលស្គាល់ដោយគណៈកម្មាធិការអន្តរជាតិនៃកាកបាទក្រហម និង
* ថ្ងៃទី៧ តុលា ១៩៦០ បានបញ្ចូលជាសមាជិកទី៨៥ របស់សហព័ន្ធអន្តរជាតិ នៃសមាគមកាកបាទក្រហម និង អឌ្ឍចន្ទក្រហម។

# ប្រវត្តិកំណើតកាកបាទក្រហមកម្ពុជា

* ខែមីនា ឆ្នាំ១៩៦១ គណៈកម្មាធិការកណ្តាលបានឯកភាពគ្នាសុំយាង សម្តេចព្រះមហាក្សត្រីយានី ស៊ីសុវត្ថិ កុសុមៈនារីរតន៍ សេរីវឌ្ឍនា (ដែលជាព្រះមាតានៃ ព្រះករុណាព្រះបរមរតនកោដ្ឋ ស្តេចគង់ប្រថាប់ជាព្រះប្រធានកិត្តិយស។
* ថ្ងៃទី៨ ខែមិថុនា ឆ្នាំ១៩៦៦ គណៈកម្មាធិការកណ្តាល បានសុំយាង ព្រះករុណា ព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ ដែលពេលនោះជា ព្រះប្រមុខរដ្ឋ ស្តេចគង់ប្រថាប់ជាព្រះប្រធានកិត្តិយស រហូតដល់ខែមីនា ឆ្នាំ១៩៧០។
* ខែធ្នូ ឆ្នាំ១៩៦៧ កាកបាទក្រមកម្ពុជា បានយាង ប្លូវម៉ែ សម្តេចព្រះវររាជមាតាជាតិខ្មែរ នរោត្តម មុនិនាថ សីហនុ ដែលពេលនោះ ជា សម្តេចព្រះរាជអគ្គមហេសី គង់ប្រថាប់ជាព្រះប្រធាន និងលោកជំទាវ ផ្លេក ភិរុណ ជាអនុប្រធានទី១។

# ប្រវត្តិកំណើតកាកបាទក្រហមកម្ពុជា

* ក្នុងដំណាក់កាលនោះ ប្លាំងម៉ែ បានព្រះរាជកិច្ចដឹកនាំពិធីរកម្មូលនិធិផ្សេងៗ យកមកជួយសម្រាលទុក្ខលំបាករបស់ប្រជានុរាស្ត្ររងគ្រោះដោយគ្រោះធម្មជាតិនានា បានចុះសួរសុខទុក្ខដល់ពលទាហានដែលរងរបួសសម្រាកព្យាបាលក្នុងមន្ទីរពេទ្យ ជួយដល់ប្រជារាស្ត្រស៊ីវិលរងគ្រោះដោយការទម្លាក់គ្រាប់បែក និងគ្រួសារភៀសសឹកនៅតាមតំបន់ព្រំដែនកម្ពុជា វៀតណាម។

* ពីឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៥ សមាគមជាតិកាកបាទក្រហមខ្មែរ មានលោកជំទាវ ជួប សំឡុត ជាប្រធាន និងលោកជំទាវ ផ្លេក ភិរុណ ជាអនុប្រធានទី១ បានបន្តបេសកកម្មជួយដល់ប្រជាជនរងគ្រោះដោយជម្លោះប្រដាប់អាវុធរវាងកម្លាំងទ័ពក្នុងរបបសាធារណរដ្ឋខ្មែរ (លន់ នល់) គាំទ្រដោយអាមេរិក និងចលនាតស៊ូរំដោះជាតិ ដឹកនាំដោយ ព្រះករុណា ព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ។

# ប្រវត្តិកំណើតកាកបាទក្រហមកម្ពុជា

* ថ្ងៃ១៨ មីនា ១៩៧០ ក្នុងស្ថានភាពសង្គ្រាមស៊ីវិលក្រោយរដ្ឋប្រហាររបបលន់នល់ សមាគមជាតិ បានបន្តស្វែងរកមូលនិធិ និងជំនួយជួយសម្រាលទុក្ខលំបាករបស់ប្រជាពលរដ្ឋភៀសសឹក ដែលមានកំណើនជារៀងរាល់ថ្ងៃ ហើយប្រជាពលរដ្ឋមួយចំនួនរងគ្រោះដោយការទម្លាក់គ្រាប់បែក/គ្រាប់ផ្លោង បានធ្លាក់ខ្លួនពិការ។
* ថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៧១ ឆ្លើយតបទៅនឹងកំណើនពិការភាព សមាគមជាតិកាកបាទក្រហមខ្មែរ បានបង្កើតឲ្យមាន មជ្ឈមណ្ឌលជាតិនីតិសម្បទា និងស្ថារលទ្ធភាពពលកម្ម ដោយមានកិច្ចសហការ និងការជួយឧបត្ថម្ភគាំទ្រពីដៃគូអន្តរជាតិ។

# ប្រវត្តិកំណើតកាកបាទក្រហមកម្ពុជា

* ពីថ្ងៃទី១៧ មេសា ១៩៧៥ រហូតមកដល់ ថ្ងៃទី៧ មករា ១៩៧៩ ជាសម័យកាលដែលតម្លៃមនុស្សធម៌ត្រូវបានជាន់ឈ្លី។
* ទីស្នាក់ការកណ្តាលរបស់សមាគមជាតិត្រូវបង្ខំឲ្យបិទទ្វារ
* បុគ្គលិកកម្ពុជាត្រូវបានជម្លៀសចេញជាមួយប្រជាជនកម្ពុជាទូទាំងប្រទេសទៅរស់នៅដូចទាសករក្រោមការគាបសង្កត់ ទាំងកាយ ស្មារតី និងត្រូវបានបង្ខំឲ្យធ្វើការជាទម្ងន់ ដោយពុំមានអាហារបរិភោគគ្រប់គ្រាន់អស់រយៈពេល ៣ឆ្នាំ ៨ខែ និង ២០ថ្ងៃ។
* ចំណែកបុគ្គលិកអន្តរជាតិវិញត្រូវបានបញ្ជូនចេញពីប្រទេសតាមស្ថានទូតបារាំង។
* អាសនៈរបស់សមាគមជាតិកាកបាទក្រហមខ្មែរ នៅក្នុងចលនាអន្តរជាតិ ត្រូវបានទុកឲ្យនៅទំនេរ។

# ប្រវត្តិកំណើតកាកបាទក្រហមកម្ពុជា

* ឆ្នាំ ១៩៧៩ ក្រោយការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ លោកជំទាវ ផ្លេក ភិរុណ ជាថ្នាក់ដឹកនាំរបស់សមាគមជាតិតែម្នាក់គត់
* លោកសាស្រ្ត. មុី សាមុីឌី ជាអ្នកស្ម័គ្រចិត្ត ដែលនៅរស់រានមានជីវិត រួចផុតពីរបបប្រល័យពូជសាសន៍។
* ឥស្សរជនទាំង២ បានចាប់ផ្តើមបង្កើតឲ្យមានសមាគមជាតិ កក្រក នៅក្នុងប្រទេសឡើងវិញ។
* នៅថ្ងៃទី១៦ ឧសភា ១៩៧៩ កក្រក ត្រូវបានរៀបចំបង្កើតឡើងវិញដោយមានរចនាសម្ព័ន្ធក្នុងក្រសួងសុខាភិបាល។
* លោកជំទាវ ផ្លេក ភិរុណ ត្រូវបានជ្រើសតាំងជាប្រធាន និងលោកសាស្រ្តាចារ្យ មុី សាមុីឌី ជាអនុប្រធាន/ និងជាអគ្គលេខាធិការ។
* កក្រក បានខិតខំអំពាវនាវ ស្វែងរកជំនួយពីអង្គការមនុស្សធម៌អន្តរជាតិនានា មកជួយសម្រាលទុក្ខលំបាករបស់ប្រជាជនកម្ពុជាក្នុងតំណាក់កាលស្តារ និងកសាងប្រទេសឡើងវិញពីបាតដៃទទេ។

# ប្រវត្តិកំណើតកាកបាទក្រហមកម្ពុជា

* ឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៩៤ កក្រក បានបាត់បង់នូវគោលការណ៍ ឯកភាព ដោយសារភាគីទំនាស់គ្នា ចំនួន៤ ដែលធ្វើសង្គ្រាមជាមួយគ្នា បានបង្កើតក្រុមកាកបាទក្រហមរៀងៗខ្លួន (រដ្ឋកម្ពុជា, ហ្វ៊ុនស៊ីនប៉ិច, រណសិរ្សរំដោះប្រជាពលរដ្ឋខ្មែរ, និងកម្ពុជាប្រជាធិបតេយ្យ)។
* អាស្រ័យហេតុនេះហើយ អាសនៈរបស់ កក្រក នៅក្នុងចលនាអន្តរជាតិ កាកបាទក្រហម និងអឌ្ឍចន្ទក្រហម ត្រូវបានបន្តរក្សាទុកឲ្យនៅទំនេរ។
* តាមស្មារតីនៃកិច្ចព្រមព្រៀងទីក្រុងប៉ារីស ថ្ងៃទី២៣ តុលា ១៩៩១ ស្តីពីការកសាងសន្តិភាព និងការបង្រួបបង្រួមជាតិ និងអនុលោមតាមគោលការណ៍គ្រឹះទី៦ ឯកភាព របស់ចលនាអន្តរជាតិកាកបាទក្រហម និងអឌ្ឍចន្ទក្រហម ព្រះករុណា ព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ ដែលពេលនោះជាព្រះប្រធានក្រុមប្រឹក្សាជាតិជាន់ខ្ពស់ (SNC) បានទ្រង់ព្រះរាជកិច្ចដឹកនាំ ពីឆ្នាំ ១៩៩២ ដល់ឆ្នាំ ១៩៩៤ ធ្វើការបង្រួបបង្រួមក្រុមកាកបាទក្រហមទាំង៤ ឲ្យទៅជាសមាគមជាតិតែមួយគត់នៅក្នុងប្រទេសឡើងវិញ ដោយមានកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយគណៈកម្មាធិការអន្តរជាតិនៃកាកបាទក្រហម (ICRC)។ ភាគីខ្មែរក្រហម បានដកខ្លួនចេញពីការបង្រួមបង្រួមគ្នា។

# ប្រវត្តិកំណើតកាកបាទក្រហមកម្ពុជា

- ពីឆ្នាំ ១៩៩២ ដល់ឆ្នាំ ១៩៩៣ កក្រក ដែលបំពេញការងារក្នុងប្រទេស បានទទួលពីរដ្ឋាភិបាលនៃរដ្ឋកម្ពុជា នូវភារកិច្ចដឹកនាំប្រតិបត្តិការមាតុភូមិនិវត្តន៍ជនភៀសខ្លួន/ជនភៀសសឹក ក្រោមកិច្ចសហការនិងការគាំទ្រពីអាជ្ញាធរបណ្តោះអាសន្នអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា (អ៊ុនតាក់)។

- ថ្ងៃទី១១ មេសា ១៩៩៤ កក្រក បានប្រារព្ធមហាសន្និបាតលើកទី១ និងបានជ្រើសតាំង ព្រះអង្គម្ចាស់ក្សត្រី នរោត្តម ម៉ារី រណឫទ្ធិ ជាប្រធាន និង សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន ជាអនុប្រធានទី១។
- មហាសន្និបាត ថែមទាំងបានអនុម័តលក្ខន្តិកៈថ្មី និងបានយាង ប្អូនម៉ែ នរោត្តម មុនិនាថ សីហនុ គង់ប្រថាប់ជា ព្រះប្រធានកិត្តិយសកាកបាទក្រហមកម្ពុជា។
- សមាគមជាតិបានបន្តប្រតិបត្តិការជួយសម្រាលទុក្ខលំបាករបស់ប្រជារាស្ត្ររងគ្រោះ ងាយរងគ្រោះ និងគ្រួសារមាតុភូមិនិវត្តន៍។

# ប្រវត្តិកំណើតកាកបាទក្រហមកម្ពុជា

- ខែកក្កដា ១៩៩៤ មហាសន្និបាតរបស់ចលនាអន្តរជាតិ កាកបាទក្រហម និងអឌ្ឍចន្ទក្រហម នាទីក្រុងហ្សឺណែវ បានប្រគល់ជូនកាកបាទក្រហមកម្ពុជាវិញនូវអាសនៈរបស់សមាគមជាតិ ដែលបានបន្តបេសកកម្មមនុស្សធម៌ជាសមាគមជាតិមានតែមួយគត់នៅក្នុងប្រទេសឡើងវិញ
- ជួយសង្គ្រោះដល់ប្រជារាស្ត្រ ដែលរងគ្រោះដោយគ្រោះធម្មជាតិ និងប្រជារាស្ត្រងាយរងគ្រោះបំផុតទាំងឡាយដោយមិនប្រកាន់ពណ៌សម្បុរ បែងចែកពូជសាសន៍ និន្នាការនយោបាយឡើយ។

- ថ្ងៃទី១០ មេសា ១៩៩៨ កក្រក បានប្រារព្ធមហាសន្និបាតលើកទី២ និងបានបោះឆ្នោតជ្រើសរើស សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន ជា ប្រធាន។
- ក្នុងឋានៈជាប្រធាន សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន បាន និងកំពុងបន្តដឹកនាំសមាគមជាតិលើមូលដ្ឋាន អភិបាលកិច្ចល្អ ដឹកនាំ គ្រប់គ្រងមានតម្លាភាព និងគណនេយ្យភាព ការអភិវឌ្ឍស្ថាប័នឲ្យសមាគមជាតិមានដំណើរការល្អ តាមរយៈការពង្រឹង/ពង្រីកសមត្ថភាពសាខា អនុសាខា កម្លាំងអ្នកស្ម័គ្រចិត្ត កក្រក។

# ប្រវត្តិកំណើតកាកបាទក្រហមកម្ពុជា

- សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន ត្រូវបានមហាសន្និបាត បោះឆ្នោតជ្រើសរើសជាប្រធានកាកបាទក្រហមកម្ពុជា ជារៀងដរាបមក៖
  - ✓ មហាសន្និបាត អាណត្តិទី៣ ថ្ងៃទី៥ ខែសីហា ឆ្នាំ២០០២-២០០៦
  - ✓ មហាសន្និបាត អាណត្តិទី៤ ថ្ងៃទី៤-៥ ខែសីហា ឆ្នាំ២០០៦-២០១០
  - ✓ មហាសន្និបាត អាណត្តិទី៥ ថ្ងៃទី៤-៥ ខែសីហា ឆ្នាំ២០១០-២០១៤
  - ✓ មហាសន្និបាត អាណត្តិទី៦ ថ្ងៃទី៦-៧ ខែសីហា ឆ្នាំ២០១៤ ដល់បច្ចុប្បន្ន

- សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន បានបន្តយាង ប្លូខម៉ែ នរោត្តម មុនិនាថ សីហនុ ស្តេចគង់ប្រថាប់ ជាព្រះប្រធានកិត្តិយស ជារៀងដរាបមក ។

# ប្រវត្តិកំណើតកាកបាទក្រហមកម្ពុជា

- ដោយមានការជួយបច្ចេកទេសពីគណៈកម្មាធិការអន្តរជាតិនៃកាកបាទក្រហម និងសហព័ន្ធអន្តរជាតិ នៃសមាគម កាកបាទក្រហម និងអឌ្ឍចន្ទក្រហម កាកបាទក្រហមកម្ពុជា បានរៀបចំឲ្យមាននូវកម្រងច្បាប់របស់សមាគមជាតិ គឺ៖

  - ព្រះរាជក្រឹត្យលេខ នស/រកត/០៥០២/១១៣ ស្តីពីការទទួលស្គាល់កាកបាទក្រហមកម្ពុជា និងព្រះរាជក្រឹត្យលេខ នស/រកត/០៥០២/១១២ ស្តីពីការទទួលស្គាល់ និងការប្រើប្រាស់បដិរូបកាកបាទក្រហម និងអឌ្ឍចន្ទក្រហម នៅកម្ពុជា ឡាយព្រះហស្តដោយ ព្រះករុណា ព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ កាលពីថ្ងៃទី៦ ខែឧសភា ឆ្នាំ ២០០២
  - លក្ខន្តិកៈកាកបាទក្រហមកម្ពុជាតាមនិយាមអន្តរជាតិ អនុម័តដោយមហាសន្និបាតវិសាមញ្ញ នៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០០។

# ប្រវត្តិកំណើតកាកបាទក្រហមកម្ពុជា

- តាមលក្ខន្តិកៈមួយនេះ កាកបាទក្រហមកម្ពុជា បានរៀបចំឲ្យមាន គណៈកម្មាធិការកណ្តាល/ គណៈកម្មាធិការសាខា ជាគណៈអភិបាល ជួយឧបត្ថម្ភគាំទ្រ ដល់ការបំពេញការងារប្រចាំថ្ងៃ របស់ក្រុមប្រតិបត្តិ ទាំងនៅថ្នាក់ណ្តាល និងនៅតាមសាខានីមួយៗ។

- ក្រោមការដឹកនាំរបស់ សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន កាកបាទក្រហកម្ពុជា មានការរីកចម្រើនក្នុងវិស័យអាទិភាពទាំង៤ នៃការបំពេញតួនាទីជាជំនួយការឲ្យអាជ្ញាធរសាធារណៈតាមទស្សន វិស័យ និងបេសកកម្ម ដែលមានចែងនៅក្នុងយុទ្ធសាស្រ្ត ២០០៣-២០១០ យុទ្ធសាស្រ្ត ២០១១-២០២០ និងយុទ្ធសាស្រ្ត ២០២១-២០៣០។

# ប្រវត្តិកំណើតកាកបាទក្រហមកម្ពុជា

- សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន បានធ្វើឲ្យមជ្ឈដ្ឋានជាតិ អន្តរជាតិទទួលស្គាល់នូវការផ្លាស់ប្តូរមុខមាត់ថ្មី កិត្តិនាម និងចាប់អារម្មណ៍យ៉ាងខ្លាំងចំពោះការអភិវឌ្ឍមានឋាមភាពរបស់កាកបាទក្រហមកម្ពុជា តាមរយៈព្រឹត្តការណ៍ធំៗ ដែលជារួមមាន៖
- ការប្រារព្ធទិវាពិភពលោកកាកបាទក្រហម និងអឌ្ឍចន្ទក្រហម ៨ ឧសភា ១៩៩៩ កត់សម្គាល់ការឆ្លងសហស្សវត្សរ៍ ដែលរៀបចំឡើងនៅមុខប្រាសាទអង្គរវត្ត ក្រោមប្រធានបទ “ **ពិភពលោកនាំគ្នារាំ** ” រួមជាមួយការបង្កើតឧទ្យានសហស្សវត្សរ៍ ដែលមានដាំដើមឈើ ២០០០ នៅតាមផ្លូវទៅតំបន់ប្រាសាទអង្គរ។
- ការប្រារព្ធទិវាពិភពលោក កាកបាទក្រហម និងអឌ្ឍចន្ទក្រហម កត់សម្គាល់ការចាប់ផ្តើមសហស្សវត្សរ៍ថ្មី នៅវត្តភ្នំ ក្រោមប្រធានបទ “ **ហ៊ានសុបិន្ត** ” និងការចាប់ផ្តើមយកការប្រារព្ធទិវាពិភពលោកកាកបាទក្រហម និងអឌ្ឍចន្ទក្រហម ៨ ឧសភា ជារៀងរាល់ឆ្នាំ ជាឱកាសនៃការរកមូលនិធិសម្រាប់ធ្វើប្រតិបត្តិការពីមួយឆ្នាំ ទៅមួយឆ្នាំ ទាំងនៅថ្នាក់កណ្តាល ទាំងនៅតាមសាខានីមួយៗ ជារៀងរហូតមក។

# ប្រវត្តិកំណើតកាកបាទក្រហមកម្ពុជា

- ក្រោមការដឹកនាំរបស់ សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន កក្រក មានឥស្សរជនជំផ្ទើម ២រូប ទទួលបានគ្រឿងឥស្សរិយយសពីអន្តរជាតិ គឺ៖

  ១- ថ្ងៃទី១១ វិច្ឆិកា ២០០១ **លោកជំទាវ ផ្លេក ភិរុណ** អតីតប្រធានកក្រក បានទទួលមេដាយហង់រី ឌុយណង់ ពីគណៈកម្មាធិការអន្តរជាតិនៃកាកបាទក្រហម នៅទីក្រុងហ្សឺណែវ។

  ២- ថ្ងៃទី២១ វិច្ឆិកា ២០០៧ **លោកសាស្ត្រាចារ្យ ម៉ី សាម៉ុឌី** ដែលពេលនោះជាអគ្គលេខាធិការកក្រក បានទទួលឥស្សរិយយស ហង់រី ដាវិដសុន ពីសហព័ន្ធអន្តរជាតិ ។

- ក្នុងកិច្ចពង្រឹងសហប្រតិបត្តិការឲ្យបានកាន់តែរឹងមាំ ជាមួយស្ថាប័នស្ថាបនិករបស់ចលនាអន្តរជាតិកាកបាទក្រហម និងអឌ្ឍចន្ទក្រហម សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន បានដឹកនាំគណៈប្រតិភូទៅទស្សនកិច្ចនៅទីក្រុងហ្សឺណែវ និងជួបសវនាការជាមួយ លោក Jacob Kallenberger ដែលពេលនោះលោកជាប្រធាន គណៈកម្មាធិការអន្តរជាតិនៃកាកបាទក្រហម និងលោក Didier Cherpitel ដែលពេលនោះ លោកជាប្រធានសហព័ន្ធអន្តរជាតិ។

- ថ្ងៃទី ៧ ដល់ថ្ងៃទី ១០ មីនា ២០០២ លោក Didier Cherpitel ប្រធានសហព័ន្ធអន្តរជាតិ បានមកទស្សនកិច្ចនៅកម្ពុជា។

# ប្រវត្តិកំណើតកាកបាទក្រហមកម្ពុជា

- ការទទួលស្គាល់ពីស្នាដៃនៃការដឹកនាំ កក្រក និងគុណតម្លៃនៃតួនាទីជាភរិយានាយករដ្ឋមន្ត្រី របស់ សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន ត្រូវបានទទួលស្គាល់ពីស្ថាប័នសហប្រជាជាតិ ដោយមានប្រគល់ជូន សម្តេចកិត្តិព្រឹទ្ធបណ្ឌិត នូវគោរមងារចំនួន ២ និងពានរង្វាន់ចំនួន ១ គឺ៖

១- ថ្ងៃទី ១៧ ខែវិច្ឆិកា ឆ្នាំ២០០៦ គោរមងារ “ ឥស្សរជនឆ្នើមថ្នាក់ជាតិនៃវេទិកាភាពជាអ្នកដឹកនាំតំបន់អាស៊ីប៉ាស៊ីហ្វិកឆ្លើយតបមេរោគអេដស៍ ជំងឺអេដស៍ និងការអភិវឌ្ឍនៅកម្ពុជា ”។

២- ថ្ងៃទី១៧ វិច្ឆិកា ២០០៩ ពានរង្វាន់ពីអង្គការសហប្រជាតិទទួលស្គាល់ស្នាដៃក្នុងការបំពេញភារកិច្ចជាឥស្សរជនឆ្នើមថ្នាក់ជាតិនៃវេទិកាភាពជាអ្នកដឹកនាំតំបន់អាស៊ីប៉ាស៊ីហ្វិកឆ្លើយតបមេរោគអេដស៍ ជំងឺអេដស៍ និងការអភិវឌ្ឍនៅកម្ពុជា ។

៣- ថ្ងៃទី២១ កុម្ភៈ ២០១១ គោរមងារ “ ឥស្សរជនឆ្នើមថ្នាក់ជាតិនៃផែនការសកម្មភាពរួមអគ្គលេខាធិការអង្គការសហប្រជាជាតិ ដើម្បីសុខភាពស្ត្រី និងកុមារ ”។

# ប្រវត្តិកំណើតកាកបាទក្រហមកម្ពុជា

- បច្ចុប្បន្ននេះ កក្រក មានសាខាតាមរាជធានី ខេត្តចំនួន២៥ មានអនុសាខាចំនួន១៩៣ នៅតាមស្រុក មានអ្នកស្ម័គ្រចិត្ត ជាង២ម៉ឺននាក់ មានយុវជន កក្រក ជាង២ម៉ឺននាក់ បាននិងកំពុងអភិវឌ្ឍ និងពង្រឹងសមត្ថភាពទាំងនៅថ្នាក់កណ្តាលទាំងនៅថ្នាក់សាខា អនុសាខា តាមទស្សនៈវិស័យ បេសកកម្ម សសរស្តម្ភ និងគុណតម្លៃ នៃយុទ្ធសាស្ត្រ ២០២១ - ២០៣០ ដែលមានទិសស្លោក សកម្មភាពនៅមូលដ្ឋាន  សម្រេចបានគោលដៅសកល  ផ្តល់សេវាកម្មជួយប្រជាពលរដ្ឋរងគ្រោះ និងងាយរងគ្រោះ តាមវិស័យអាទិភាពចំនួន ៤ គឺ៖

  - ការគ្រប់គ្រងគ្រោះមហន្តរាយ វិបត្តិភ័យ និងការប្រែប្រួលអាកាសធាតុ
  - សុខភាព និងការថែទាំសុខភាពក្នុងសហគមន៍
  - ការលើកកម្ពស់គោលការណ៍គ្រឹះ និងតម្លៃមនុស្សធម៌
  - ការអភិវឌ្ឍស្ថាប័ន

# រចនាសម្ព័ន្ធទីស្នាក់ការកណ្តាលកាកបាទក្រហមកម្ពុជា



# រចនាសម្ព័ន្ធសាខាកាកបាទក្រហមកម្ពុជា

**កម្រិតអប្បបរមា**



# រចនាសម្ព័ន្ធសាខាកាកបាទក្រហមកម្ពុជា

**កម្រិតអភិវឌ្ឍទី១**

**គណៈកម្មាធិការសាខា**

ប្រធាន អនុប្រធាន ហេរញ្ញិក លេខាធិការ សមាជិក-សមាជិកា

**នាយកសាខា**

**នាយករង (១រូប)**

### ការិយាល័យ រដ្ឋបាល-ហិរញ្ញកិច្ច

- ការងាររដ្ឋបាល-ហិរញ្ញកិច្ច
- គ្រប់គ្រងទិន្នន័យបុគ្គលិក សមាជិកភាព អ្នកស្ម័គ្រចិត្ត និងយុវជនកក្រក
- កសាងផែនការ ពិនិត្យតាមដាន វាយតម្លៃ និងអនុវត្តរបបរាយការណ៍ទៀងទាត់

### ការិយាល័យអភិវឌ្ឍន៍

- ការងារអភិវឌ្ឍន៍ស្ថាប័ន
- ផ្សព្វផ្សាយចលនា គោលការណ៍គ្រឹះ ច្បាប់មនុស្សធម៌អន្តរជាតិ
- អភិវឌ្ឍន៍យុវជន និងអ្នកស្ម័គ្រចិត្ត កក្រក
- ពង្រីកសមាជិកភាព និងកៀរគររកមូលនិធិ

### ការិយាល័យសុខភាព និងគ្រប់គ្រងគ្រោះមហន្តរាយ

- ការងារត្រៀមបង្ការ និងឆ្លើយតបគ្រោះមហន្តរាយ
- អភិវឌ្ឍន៍សុខភាពសហគមន៍
- គម្រោង កម្មវិធី ឯទៀត

| | | | | | | |
|---|---|---|---|---|---|---|
| គណៈកម្មាធិការ អនុសាខា | គណៈកម្មាធិការ អនុសាខា | គណៈកម្មាធិការ អនុសាខា | គណៈកម្មាធិការ អនុសាខា | គណៈកម្មាធិការ អនុសាខា | គណៈកម្មាធិការ អនុសាខា | គណៈកម្មាធិការ អនុសាខា |

មន្ត្រីប្រចាំការ ក្រុមកាកបាទក្រហម អ្នកស្ម័គ្រចិត្ត យុវជនកាកបាទក្រហមកម្ពុជា

# រចនាសម្ព័ន្ធសាខាកាកបាទក្រហមកម្ពុជា

## កម្រិតអភិវឌ្ឍទី២

**គណៈកម្មាធិការសាខា**

ប្រធាន អនុប្រធាន ហេរញ្ញិក លេខាធិការ សមាជិក-សមាជិកា

**នាយកសាខា**

**នាយករង** (២រូប)

### ការិយាល័យ រដ្ឋបាល-ហិរញ្ញកិច្ច

- ការងាររដ្ឋបាល-ហិរញ្ញកិច្ច
- គ្រប់គ្រងទិន្នន័យបុគ្គលិក សមាជិកភាព អ្នកស្ម័គ្រចិត្ត និងយុវជនកក្រក
- កសាងផែនការ ពិនិត្យតាមដាន វាយតម្លៃ និងអនុវត្តរបបរាយការណ៍ទៀងទាត់

### ការិយាល័យ អភិវឌ្ឍន៍

- ការងារអភិវឌ្ឍន៍ស្ថាប័ន
- អភិវឌ្ឍន៍យុវជន និងអ្នកស្ម័គ្រចិត្តកក្រក

### ការិយាល័យទំនាក់ទំនង និងរកចំណូល

- ផ្សព្វផ្សាយចលនា គោលការណ៍គ្រឹះ ច្បាប់មនុស្សធម៌អន្តរជាតិ ពង្រីកសមាជិកភាព និងកៀរគរមូលនិធិ
- ទំនាក់ទំនងសាធារណៈ
- អាជីវកម្ម សេវាកម្មរកចំណូល
- អភិវឌ្ឍន៍ដៃគូ សហប្រតិបត្តិការ

### ការិយាល័យសុខភាព និងគ្រប់គ្រងគ្រោះមហន្តរាយ

- ត្រៀមបង្ការ និងឆ្លើយតបគ្រោះមហន្តរាយ
- អភិវឌ្ឍន៍សុខភាពសហគមន៍
- គម្រោង កម្មវិធី ឯទៀត

គណៈកម្មាធិការ អនុសាខា | គណៈកម្មាធិការ អនុសាខា | គណៈកម្មាធិការ អនុសាខា | គណៈកម្មាធិការ អនុសាខា | គណៈកម្មាធិការ អនុសាខា | គណៈកម្មាធិការ អនុសាខា | គណៈកម្មាធិការ អនុសាខា

មន្ត្រីប្រចាំការ ក្រុមកាកបាទក្រហម អ្នកស្ម័គ្រចិត្ត យុវជនកាកបាទក្រហមកម្ពុជា

# មុខងារ និងភារកិច្ច

កាកបាទក្រហមកម្ពុជា មានមុខងារ និងភារកិច្ច ដូចតទៅ ៖
រួមចំណែកកាត់បន្ថយភាពក្រីក្រ ការពារសេចក្តីថ្លៃថ្នូរ របស់មនុស្សជាតិ និងការពារតម្លៃមនុស្សធម៌របស់ជនរងគ្រោះ សម្រេចឲ្យបាននូវយុទ្ធសាស្ត្រ ដូចមានចែងក្នុងបេសកកម្ម ជាសមាគមជាតិនាំមុខគេក្នុងវិស័យមនុស្សធម៌ កាកបាទក្រហមកម្ពុជា ប្រមូលផ្តុំកម្លាំងមនុស្សធម៌ ដើម្បីបន្តជួយដល់ជនរងគ្រោះបំផុត តាមរយៈការគ្រប់គ្រងគ្រោះមហន្តរាយ សុខភាព និងការថែទាំសុខភាពសហគមន៍ និងការលើកកម្ពស់គោលការណ៍គ្រឹះ និងតម្លៃមនុស្សធម៌របស់ចលនា នឹងបានកំណត់ទិសយុទ្ធសាស្ត្រ ចំនួន ៤ គឺ ៖

# មុខងារ និងភារកិច្ច

## ទស្សនវិស័យ បេសកកម្ម សសរស្តម្ភ និងគុណតម្លៃ

១. វិស័យអាទិភាពការគ្រប់គ្រងគ្រោះមហន្តរាយ វិបត្តិភ័យនិងការប្រែប្រួលអាកាសធាតុ

២. វិស័យអាទិភាពសុខភាពនិងការថែទាំសុខភាពក្នុងសហគមន៍

៣. វិស័យអាទិភាពការលើកកម្ពស់គោលការណ៍គ្រឹះនិងតម្លៃមនុស្សធម៌

៤. វិស័យអាទិភាពការអភិវឌ្ឍស្ថាប័ន

# មុខងារ និងភារកិច្ច

អនុវត្តឲ្យបានតាមបាវចនា “ **ធ្វើឲ្យបានកាន់តែច្រើនជាងមុន ធ្វើឲ្យបានកាន់តែល្អជាងមុន ធ្វើឲ្យបានកាន់តែស៊ីជម្រៅជាងមុន និងទៅឲ្យបានកាន់តែឆ្ងាយជាងមុន** ” ។

**កំណត់សម្គាល់ ៖**

- គណៈកម្មាធិការកណ្តាល ជួបប្រជុំសាមញ្ញ រៀងរាល់ ៦ ខែម្តង ( មាត្រា ១៦ )
- គណៈកម្មាធិការកណ្តាល កោះប្រជុំវិសាមញ្ញ តាមការចាំបាច់
- គណៈកម្មាធិការកណ្តាល ជួបប្រជុំជាមួយគណៈកម្មាធិការសាខា រៀងរាល់ឆ្នាំ (តាមស្មារតីនៃអង្គមហាសន្និបាតអាណត្តិទី ៦ )

# គណៈអភិបាល នៅថ្នាក់សាខា អនុសាខា

**គណៈកិត្តិយសសាខា គណៈកិត្តិយសអនុសាខា** ទទួលការតែងតាំងពី គណៈកម្មាធិការកណ្តាលកាកបាទក្រហមកម្ពុជា តាមការស្នើសុំរបស់គណៈកម្មាធិការសាខា។ គឺជាឥស្សរជន កំពុងបំពេញធុរកិច្ចក្នុងរដ្ឋបាលដែនដីរបស់ខ្លួន ជាអ្នកផ្តល់នូវកិត្តិនាម ដល់កាកបាទក្រហមកម្ពុជា ពិសេសជាអ្នកសម្របសម្រួលទ្រទ្រង់ និងកៀរគររកមូលនិធិ ដើម្បីសាខា អនុសាខា មានលទ្ធភាពបំពេញតម្រូវការ ដើម្បីសម្រេចបាននូវសកម្មភាពមនុស្សធម៌របស់ខ្លួន។ គណៈកិត្តិយសសាខា អនុសាខា (ក្នុងពេលបំពេញភារកិច្ច) ត្រូវគោរព និងប្រតិបត្តិតាមគោលនយោបាយ និងបទប្បញ្ញត្តិនានារបស់កាកបាទក្រហម កម្ពុជា។ (មាត្រា ២៤ មាត្រា ២៥ និងវិធានទី ៣១.៤)

# គណៈអភិបាល នៅថ្នាក់សាខា អនុសាខា

**គណៈកម្មាធិការសាខា អនុសាខា** ជាគណៈអភិបាលរបស់សាខា អនុសាខា ដែលត្រូវបានបោះឆ្នោតជ្រើសរើស ដោយសន្និបាតសាខា អនុសាខា នៅរៀងរាល់ ៦ ឆ្នាំម្តង មានភារកិច្ចទទួលការងារអភិបាល គឺមិនប្រឡូកក្នុងការងារជំនាញប្រចាំថ្ងៃ តែត្រូវធានាថា សាខា អនុសាខា ត្រូវបានគ្រប់គ្រងយ៉ាងល្អ និងជាអ្នកចង្អុលទិស ផ្តល់ការគាំទ្រដល់ក្រុមប្រតិបត្តិសាខា អនុសាខា ក្រុមកាកបាទក្រហមកម្ពុជា បណ្តាញយុវជន និងអ្នកស្ម័គ្រចិត្តកាកបាទក្រហមកម្ពុជា។ ជាពិសេសបំពេញបង្គ្រប់ ឲ្យគ្នាទៅវិញ ទៅមក រវាងគណៈកម្មាធិការសាខា អនុសាខា និងក្រុមប្រតិបត្តិសាខា។

(មាត្រា ២៤ មាត្រា ២៥ និងវិធានទី ៣១.៥ និង វិធានទី ៤៦.៤)។

# គណៈអភិបាល នៅថ្នាក់សាខា អនុសាខា

* **គណៈកម្មាធិការសាខា** ប្រជុំសាមញ្ញយ៉ាងហោចណាស់ ៣ ខែម្តង (វិធាន ទី៤៣.១)

* **គណៈកម្មាធិការសាខា** ប្រជុំជាមួយគណៈកម្មាធិការអនុសាខា យ៉ាងហោចណាស់ ៦ ខែម្តង។

* **គណៈកម្មាធិការសាខា** ប្រជុំជារៀងរាល់ (១ ឆ្នាំ ម្តង) ជាមួយគណៈកម្មាធិការកណ្តាល។

* **គណៈកម្មាធិការសាខា** ត្រូវរៀបចំចាត់តាំងក្រុមការងារសវនកម្មផ្ទៃក្នុង ដែលមានសមាសភាពពី ២ ទៅ ៣ រូប ជាសមាជិកគណៈកម្មាធិការសាខា ក្នុងនោះមានហេរញ្ញិក។ (បទប្បញ្ញត្តិហិរញ្ញវត្ថុទី ១២)។

# គណៈអភិបាល នៅថ្នាក់អនុសាខា

**គណៈកម្មាធិការអនុសាខា** ជាគណៈអភិបាល នៃអនុសាខា(ដែលត្រូវបានបោះឆ្នោតជ្រើសរើស ដោយសន្និបាតអនុសាខា) មានភារកិច្ចទទួលការងារអភិបាល បំពេញមុខងារ តាមការប្រគល់ឲ្យរបស់គណៈកម្មាធិការសាខា។ **ត្រូវរៀបចំអគារ ឬ បន្ទប់ការិយាល័យ ដាច់ដោយឡែក និងមាននិមិត្តសញ្ញាកាកបាទក្រហមកម្ពុជា**។ (មាត្រាទី៦ នៃព្រះរាជក្រឹត្យ) និងចាត់តាំងមន្ត្រីប្រចាំការ តាមតម្រូវការចាំបាច់ និងតាមលទ្ធភាព។

# គណៈអភិបាល នៅថ្នាក់អនុសាខា

## គណៈកម្មាធិការ អនុសាខា មានភារកិច្ច ៖

១- ត្រូវជំរុញការពង្រីកសមាជិកភាព ឆ្ពោះទៅគោលដៅអប្បបរមា ១% (មួយភាគរយ) នៃចំនួនប្រជាពលរដ្ឋរួម។ (វិធានទី ៤៦.៧)

២- ទ្រទ្រង់ក្រុមកាកបាទក្រហមកម្ពុជា បណ្តាញយុវជន និងអ្នកស្ម័គ្រចិត្តកាកបាទក្រហមកម្ពុជា ក្នុងរដ្ឋបាលដែនដីរបស់ខ្លួន។

៣- កៀរគររកសប្បុរជន និងមូលនិធិ។

៤- ស្រង់ស្ថិតិ និងរាយការណ៍ អំពីជនរងគ្រោះ និងងាយរងគ្រោះ នៅពេលមានគ្រោះមហន្តរាយ ឬឧបទ្ទវហេតុផ្សេងៗកើតឡើងជូនសាខា។ (មាត្រា ២៥)

៥- ជួយជនងាយរងគ្រោះ និងរងគ្រោះ ឲ្យទាន់ពេលវេលា និងមានប្រសិទ្ធភាព។

# ក្រុមកាកបាទក្រហមកម្ពុជា ឃុំ - សង្កាត់

**ក្រុមកាកបាទក្រហមកម្ពុជា ឃុំ-សង្កាត់** ទទួលការតែងតាំងពីគណៈ កម្មាធិការសាខា តាមការស្នើសុំរបស់គណៈកម្មាធិការអនុសាខា។ **ក្រុមកាកបាទក្រហមកម្ពុជា ឃុំ-សង្កាត់** មានសមាជិក ចាប់ពី ២ (ពីរ) នាក់ ឡើងទៅ ក្នុងឃុំ-សង្កាត់នីមួយៗ ហើយត្រូវទទួលខុសត្រូវជាបឋមចំពោះមុខ គណៈកម្មាធិការអនុសាខា និងគណៈកម្មាធិការសាខា បំពេញការងារជាជំនួយការឲ្យអាជ្ញាធរសាធារណៈ ក្នុងវិស័យមនុស្សធម៌។

# ក្រុមកាកបាទក្រហមកម្ពុជា ឃុំ - សង្កាត់

**ក្រុមកាកបាទក្រហមកម្ពុជា ឃុំ-សង្កាត់** មានភារកិច្ច៖

១- គ្រប់គ្រងទិន្នន័យប្រជាពលរដ្ឋងាយរងគ្រោះ។

២- ស្រង់ស្ថិតិ និងរាយការណ៍ជូនអនុសាខា អំពីជនរងគ្រោះ និងងាយរងគ្រោះនៅពេលមានគ្រោះមហន្តរាយ ឬឧបទ្ទវហេតុផ្សេងៗកើតឡើង និងចូលរួមឆ្លើយតបជាមួយអនុសាខាឲ្យមានប្រសិទ្ធភាព។

៣- តម្រង់គោលដៅ ឆ្ពោះទៅមានសមាជិកភាពអប្បបរមា ១% (មួយភាគរយ) នៃចំនួនប្រជាពលរដ្ឋរួម ក្នុងឃុំ-សង្កាត់របស់ខ្លួន។ (វិធានទី ៤៩.៥)

៤- ទទួលខុសត្រូវគ្រប់គ្រង ទិន្នន័យយុវជន និងអ្នកស្ម័គ្រចិត្តកាកបាទក្រហមកម្ពុជា ក្នុងមូលដ្ឋានរបស់ឃុំ-សង្កាត់នីមួយៗ ទំនាក់ទំនង និងធ្វើរបាយការណ៍ឲ្យបានទៀងទាត់ជូនអនុសាខា។

# ក្រុមប្រតិបត្តិនៅថ្នាក់សាខា

**ក្រុមប្រតិបត្តិសាខា** ជាអ្នកគ្រប់គ្រង និងបំពេញការងារជំនាញប្រចាំថ្ងៃ តាមគោលដៅផែនការសកម្មភាព ដែលបានកំណត់ដោយគណៈកម្មាធិការសាខា សំដៅសម្រេចឲ្យបាននូវលទ្ធផលដែលបានគ្រោងទុក។ ក្នុងប្រតិបត្តិការជាក់ស្តែង ក្រុមប្រតិបត្តិចាំបាច់ត្រូវពិភាក្សាសុំគោលការណ៍ និងការសម្រេចឯកភាពពីគណៈកម្មាធិការសាខា។

# កាកបាទក្រហមកម្ពុជា

CAMBODIAN RED CROSS

## យុទ្ធសាស្ត្រ ២០២១ - ២០៣០

### ទស្សនវិស័យ បេសកកម្ម សសរស្តម្ភ និងគុណតម្លៃ

១. វិស័យអាទិភាពការគ្រប់គ្រងគ្រោះមហន្តរាយ វិបត្តិភ័យនិងការប្រែប្រួលអាកាសធាតុ

២. វិស័យអាទិភាពសុខភាពនិងការថែទាំសុខភាពក្នុងសហគមន៍

៣. វិស័យអាទិភាពការលើកកម្ពស់គោលការណ៍គ្រឹះនិងតម្លៃមនុស្សធម៌

៤. វិស័យអាទិភាពការអភិវឌ្ឍស្ថាប័ន

# យុទ្ធសាស្រ្ត ២០២១ - ២០៣០

## ទស្សនវិស័យ

កក្រក ដែលជាស្ថាប័នមនុស្សធម៌នាំមុខគេនៅកម្ពុជា នឹងក្លាយជាសមាគមជាតិដែលមានភាពម្ចាស់ការខ្ពស់។

## បេសកកម្ម

កក្រក ប្រមូលផ្តុំកម្លាំងមនុស្សធម៌ដើម្បីចូលរួមលើកកម្ពស់ជីវភាពរបស់ជនងាយរងគ្រោះបំផុតនិងជនរងគ្រោះតាមរយៈវិស័យអាទិភាពចំនួន៤រួមមាន៖

១- ការគ្រប់គ្រងគ្រោះមហន្តរាយ វិបត្តិភ័យនិងការប្រែប្រួល អាកាសធាតុ

២- សុខភាពនិងការថែទាំសុខភាពក្នុងសហគមន៍

៣- ការលើកកម្ពស់គោលការណ៍គ្រឹះនិងតម្លៃមនុស្សធម៌ និង

៤- ការអភិវឌ្ឍស្ថាប័ន។

# យុទ្ធសាស្ត្រ ២០២១ - ២០៣០

## សសរស្តម្ភ

១. មូលដ្ឋានច្បាប់ និងរចនាសម្ព័ន្ធ

២. កម្មវិធី និងសេវាម្មប្រកបដោយគុណភាព

៣. និរន្តរភាពនៃកម្មវិធី និងសេវាកម្ម

៤. ការអភិវឌ្ឍចំណុចស្នូល

# គុណតម្លៃ


គុណតម្លៃទាំង៧
ការប្តេជ្ញាចិត្ត
តម្លាភាព និង គណនេយ្យភាព
ប្រសិទ្ធភាព/ ប្រសិទ្ធផល
ជំនឿទុកចិត្ត
បរិយាប័ន្ន
ការទទួលស្គាល់
ការត្រៀមខ្លួនជាស្រេច

## ១. វិស័យអធិភាពការគ្រប់គ្រងគ្រោះមហន្តរាយ វិបត្តិភ័យ និង ការប្រែប្រួលអាកាសធាតុ

១- ការងារត្រៀមឆ្លើយតបគ្រោះហន្តរាយ
២- ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ
៣- ការឆ្លើយតបគ្រោះមហន្តរាយ
៤- ការស្តារឡើងវិញ
៥- ការលើកកម្ពស់សុវត្ថិភាពចរាចរណ៍

## ២. វិស័យអាទិភាព សុខភាព និងការថែទាំសុខភាពក្នុងសហគមន៍

១- ការងារតស៊ូសរជនធ្វើមថ្នាក់ជាតិ

១.១. *សុខភាពមាតា ទារកនិងកុមារ*

១.២. *មេរោគអេដស៍ និងជំងឺអេដស៍*

២- សុខភាពគ្រាអាសន្ន

៣- វិជ្ជាសង្គ្រោះបឋម

៤- សុខភាពសហគមន៍

## ៣. វិស័យអាទិភាព ការលើកកម្ពស់គោលការណ៍គ្រឹះ និងតម្លៃមនុស្សធម៌

១- ការលើកកម្ពស់ការយល់ដឹងអំពីគុណតម្លៃរបស់ចលនា

២- ការលើកកម្ពស់សេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ

៣- លើកកម្ពស់វប្បធម៌អហិង្សានិងសន្តិភាព

៤- លើកកម្ពស់សុខុមាលភាពសង្គម

## ៤. វិស័យអាទិភាពការអភិវឌ្ឍស្ថាប័ន

១- ការអភិបាល និង ការគ្រប់គ្រង

២- ការអភិវឌ្ឍសាខា-អនុសាខា

៣- ការគ្រប់គ្រងនិងការអភិវឌ្ឍធនធានមនុស្ស
*(មន្ត្រី-បុគ្គលិក យុវជន អ្នកស្ម័គ្រចិត្ត កក្រក)*

៤- ការអភិវឌ្ឍធនធានហិរញ្ញវត្ថុ

៥- ការងារទំនាក់ទំនង និង កិច្ចសហប្រតិបត្តិការ

៦- ការអភិវឌ្ឍការងាររដ្ឋបាល-ហិរញ្ញកិច្ច

៧- ការកសាងផែនការពិនិត្យតាមដាន វាយតម្លៃនិងរបាយការណ៍

# កាកបាទក្រហមកម្ពុជា

CAMBODIAN  RED CROSS


អាសយដ្ឋាន៖ ឡូត៍១៦អា ផ្លូវលេខ ៦៥២ កែងផ្លូវ ២៧១ អូរបែកក្អម សង្កាត់ទឹកល្អក់ ៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ

ទូរស័ព្ទ៖ ០២៣ ៨៨១ ៥១១

អ៊ីមែល៖ info@redcross.org.kh / crc_adm@online.com.kh

ហ្វេសប៊ុក៖ www.facebook.com/crcnhq

គេហទំព័រ៖ www.redcross.org.kh

ប្រព័ន្ធសិក្សា៖ www.elearning-crc.org.kh